**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : 1972 PC.អក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្គត់ផ្គង់សំភារៈ(កញ្ចប់លេខ២៣) សំរាប់ ប្រើប្រាស់ក្នុងរោងជាងមេកានិកខ្សែបញ្ជូនអគ្គិសនី ជូនអង្គភាពបណ្តាញបញ្ជូននៃនាយកដ្ឋានបញ្ជូនអគ្គិសនី

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តា ក្រុមហ៊ុន/សហគ្រាស( គិតទាំងសហគ្រាស ឯកត្តបុគ្គល ) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា:អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សំភារៈ( កញ្ចប់លេខ២៣) សំរាប់ប្រើប្រាស់ក្នុងរោងជាងមេកានិកខ្សែបញ្ជូនអគ្គិសនី ជូនអង្គភាពបណ្តាញបញ្ជូន នៃ នាយកដ្ឋានបញ្ជូនអគ្គិសនី ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន /សហគ្រាសបំពេញ ដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាស័យដ្ឋាន: ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ : 023 67 66 007 និង Website : ( www.edc.com.kh) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៧ វេលាម៉ោង ១១:00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើវេលាម៉ោង ១៥:៤៥នាទី ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និង សាកសួរពត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី 30 ខែ សីហា ឆ្នាំ ២០១៧

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឆឹង អ៊ីង**

ចម្លងជូន :

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ